# សិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់លើកទី២

## "ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម, អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ៖ លទ្ធផលពាក់កណ្តាល គម្រោង ការត្រួតពិនិត្យ, វាយតម្លៃ និងផលប៉ះពាល់ នៃគម្រោង CEDEP I និង CEDEP II ក្រោមកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម"

ខេត្តបាត់ដំបង ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១៥

## សុន្ទរកថាស្វាគមន៍ ដោយ ឯ.ឧ អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង

**ឯកឧត្តម លោកជំទាវ**
**មន្ត្រីដែលអញ្ជើញមកពីក្រសួងពាណិជ្ជកម្ម**
**តំណាងមកពីមន្ទីរខេត្ត**
**មន្ត្រីទំនាក់ទំនង និង សមាជិកក្រុមការងារស្នូល**
**អ្នកទទួលផលពីគម្រោង**
**លោក លោកស្រី នាងកញ្ញា**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយ ដែលបានអញ្ជើញចូលរួមជាអធិបតី និងថ្លែងសន្ទរកថាស្វាគមន៍ នៅក្នុងកម្មវិធីសិក្ខាសាលាថ្នាក់តំបន់ ស្តីពី "ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម, អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម៖ លទ្ធផលពាក់កណ្តាលគម្រោង ការត្រួតពិនិត្យ, វាយតម្លៃ និងផលប៉ះពាល់នៃគម្រោងពិពិធកម្ម និងពង្រីកការនាំចេញរបស់កម្ពុជាជំហ៊ានទី១ និងទី២ (CEDEP I & II) ក្រោមកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម"។

ក្នុងនាមខ្ញុំ និងតំណាងឲ្យថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធក្នុងខេត្តបាត់ដំបងទាំងមូល ខ្ញុំសូមសំដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះក្រសួងពាណិជ្ជកម្ម ដែលបានជ្រើសយកខេត្តបាត់ដំបង យើងខ្ញុំសម្រាប់រៀបចំសិក្ខាសាលាផ្សព្វផ្សាយដ៏មានសារៈសំខាន់នាថ្ងៃនេះ។ ជាពិសេស ចំពោះវត្តមានរបស់ **ឯកឧត្តម ច័ន្ទ និត្យរ៉ាម៉ូ អនុរដ្ឋលេខាធិកា ក្រសួងពាណិជ្ជកម្ម** និង លោក លោកស្រី នាងកញ្ញា ដែលអញ្ជើញមកពីក្រសួងស្ថាប័ននៅថ្នាក់ជាតិ, ថ្នាក់ក្រោមជាតិ (មន្ទីរសភាពាណិជ្ជកម្ម, មន្ទីរពាណិជ្ជកម្ម, មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ, មន្ទីរឧស្សាហកម្ម និងសិប្បកម្ម, មន្ទីរកិច្ចការនារី, មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរទេសចរណ៍ នៃខេត្តទាំងប្រាំពីរមាន (ខេត្តបាត់ដំបង, សៀមរាប,បន្ទាយមានជ័យ,ប៉ៃលិន,ពោធិសាត់, កំពង់ឆ្នាំង និងខេត្តឧត្តរមានជ័យ), និងវិស័យឯកជន ដែលជាអ្នកទទួលផលពីគម្រោងដោយផ្ទាល់។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជំម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា** ពីស្ថានភាពទូទៅ និងសក្តានុពលសំខាន់ៗរបស់ខេត្តបាត់ដំបងដូចតទៅ ៖

- 
- 
- 

ជាថ្មីម្តងទៀត ជំនួសមុខអោយអាជ្ញាធរខេត្ត ខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹងចំពោះការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម, អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្មៈ លទ្ធផលពាក់កណ្តាលគម្រោង ការត្រួតពិនិត្យ, វាយតម្លៃ និងផលប៉ះពាល់ គម្រោង CEDEP I និង CEDEP II ក្រោមកម្មវិធីពង្រឹងក្របខណ្ឌសមាហរណកម្ម" ដែលជាព្រឹត្តការណ៍ដ៏មានសារៈសំខាន់សម្រាប់ស្ថាប័ន និងភាគីពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ជាពិសេសសម្រាប់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៅក្នុងខេត្តបាត់ដំបង ឲ្យទទួលបាននូវព័តមាន និងចំណេះដឹងថ្មីៗបន្ថែមទៀត ដើម្បីចូលរួមគាំទ្រដល់ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជម្រុញ និងលើកកម្ពស់ការចូលរួមរបស់ស្ថាប័នរដ្ឋ វិស័យឯកជន សហគ្រាសខ្នាតតូច និងមធ្យម ដើម្បីបង្កើនផលិតភាព, ការធ្វើពិពិធកម្ម និងពង្រីកការនាំចេញ ផលិតផលសក្តានុពលរបស់កម្ពុជា ទៅកាន់ទីផ្សារក្នុងតំបន់និងអន្តរជាតិឲ្យបានកាន់តែច្រើនបន្ថែមទៀត។

ជាចុងបញ្ចប់នេះ ខ្ញុំ សូមថ្លែងអំណរគុណដល់ **ឯកឧត្តម អនុរដ្ឋលេខាធិការ** លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាចូលរួមសិក្ខាសាលា និងបានមកស្នាក់នៅលើទឹកដីខេត្តបាត់ដំបងក្នុងរយៈប៉ុន្មានថ្ងៃនេះ។ ខ្ញុំសូមជូនពរ លោកជំទាវ លោក លោកស្រី គណៈអធិបតី និងភ្ញៀវកិត្តិយសទាំងអស់ មានសុខភាពល្អ សិរីសួស្តី និងជួបប្រទះតែពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

***សូមអរគុណ!***

***